

# សហគមន៍ចូលរួមក្នុងការគ្រប់គ្រង ធនធានជលផល

ករណីសិក្សា

នៅភូមិត្បូងខ្លា និងអូរម្រះក្នុងខេត្តស្ទឹងត្រែង

នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ និងចងក្រងដោយៈ

លោក ឈៃ គឹមសេង

លោក ង ស៊ីវ៉ាប្ប

សំរបសំរួលដោយៈ

លោក អ៊ុល គឹមសា

២០០២

# សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល

**ករណីសិក្សា**

នៅភូមិត្បូងខ្លា និងអូរម្រះក្នុងខេត្តស្ទឹងត្រែងនៃព្រះរាជាណាចក្រកម្ពុជា

**ស្រាវជ្រាវ និងចងក្រងដោយ:**

លោក ខៃ ស៊ីរ៉ាបូ

លោក ថៃ គីមសេង

**អ្នកសំរបសំរួលដោយ:**

លោក អ៊ុល គិមសា

**២០០២**

ករណីសិក្សានេះ មានគោលបំណងចងក្រងជាឯកសារអំពីការចូលរួមគ្រប់គ្រងលើធនធានជលផលរបស់ អ្នកភូមិត្បូងខ្លា និងអូរម្រះក្នុងខេត្តស្ទឹងត្រែង។ ធនធានជលផល គឺជាប្រភពអាហារចំបងសំរាប់ការរស់នៅរបស់ប្រជាជនក្នុងស្រុក ពិសេសប្រជាពលរដ្ឋប្រមាណ ៩០ ភាគរយដែលកំពុងរស់នៅតំបន់ជនបទត្រូវការត្រីជាចាំបាច់។ កន្លងមកក្នុងកំឡុងឆ្នាំ ១៩៨៥ ដល់ ១៩៩៨ តំបន់នេសាទនៅក្នុងខេត្តស្ទឹងត្រែង បានប្រឈមមុខនិងការបំផ្លាញធនធានជលផលយ៉ាងខ្លាំង។ ការអូសបន្លាយនៃសង្គ្រាមស៊ីវិល ការធ្វើអាជីវកម្មលើធនធានហួសកំរិត សំពាធពីអ្នកខាងក្រៅ កង្វះខាតការគ្រប់គ្រង និងការអនុវត្តច្បាប់នៅមានកំរិត។ ហេតុនេះ ការថយចុះនៃធនធានត្រីបានបណ្តាលអោយជះឥទ្ធិពលយ៉ាងខ្លាំងលើជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកភូមិ ព្រមទាំងបានបង្កើនភាពក្រីក្រថែមទៀត។

ចំពោះហេតុផលទាំងនេះ បានជំរុញអោយសហគមន៍មូលដ្ឋានចូលរួមរៀបចំសហគមន៍នេសាទ ដោយមានការឧបត្ថម្ភពីអង្គការ អូស៊ីអេអេ ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(ការិយាល័យជលផល)។ ដូចនេះផងដែរ សហគមន៍មូលដ្ឋានមានការចាប់អារម្មណ៍ក្នុងការថែរក្សានូវធនធានទាំងនេះ ពីព្រោះថាបានបង្ហាញសញ្ញានៃការកាត់បន្ថយនូវបទល្មើសនេសាទ មានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងបានទទួលផលប្រយោជន៍ពីការរៀបចំសហគមន៍នេសាទនេះ ពិសេស សហគមន៍មូលដ្ឋានយល់ដឹងនូវការប្រើប្រាស់ធនធានត្រីប្រកបដោយនិរន្តភាព ព្រមទាំងបានចូលរួមក្នុងការគ្រប់គ្រងធនធានជលផលទៀតផង។

OCAA RECOFTC IDRC CRDI CANADA Oxfam America WWF

**ស្រាវជ្រាវ និងចងក្រងដោយ :**

លោក ខៃ ស៊ីភាំបូ

មន្ត្រីសមាសភាគីជាមួយអង្គការសហគមន៍ជំនួយបរទេស

លោក ថៃ គីមសេង

មន្ត្រីជំនួយការនៃអង្គការសហគមន៍ជំនួយបរទេស

**អ្នកសរសេរសម្រួលដោយ :**

លោក អ៊ុល គិមស៊ា

មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល

សមាសភាគីជាមួយគំរោងស្តីពី " ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

នៃអង្គការ WWF

**ទីប្រឹក្សា :**

កញ្ញា ហ៊ុ គល្យាណ

លោក ស្រី មារ៉ូណា

លោក ឆួម យ៉េង

លោកជូ ប៊ីខាហ្ស៊ីន

**អ្នកកែសម្រួលដោយៈ**

កញ្ញា រេបិកកា គីនណាកីន

លោក កែន អាវីន

លោក កែនទិត វិប៊ី

**ឧបត្ថម្ភដោយអង្គការៈ**

-សហគមន៍ជំនួយបរទេស

-គំរោងករណីសិក្សា" ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" នៃអង្គការ WWF

-មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍

-មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់

-អង្គការអុកស្វាមអាមេរិកាំង

# អារម្ភកថា

## ដំណើរការករណីសិក្សា

ដោយទទួលស្គាល់ថា ការគ្រប់គ្រងធនធានដោយសហគមន៍ (CBNRM) គឺជាទស្សនៈ និងការអនុវត្តថ្មីមួយ ចំពោះប្រទេសកម្ពុជា ការចងក្រងឯកសារអំពីបទពិសោធន៍មូលដ្ឋាន និងមេរៀនដែលទទួលនេះបង្កើតចេញជាសមាសភាគសំខាន់មួយនៃការវិភាគ និងការចែករំលែកពត៌មានរវាងសហគមន៍មូលដ្ឋាន គំរោង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទង CBNRM នេះ ។

ការចងក្រងករណីសិក្សានេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរៀនសូត្រចម្រុះមួយ (ដោយផ្អែកលើគំរូវដ្តរៀនសូត្រដែលជាបទពិសោធន៍មួយ) ដែលមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០១ ដល់ ខែវិច្ឆិកា ឆ្នាំ ២០០២ និងអាចមានរយៈពេលយូរជាងនេះទៅទៀត ។ ការបណ្តុះបណ្តាលដំបូងអំពីការសរសេរករណីសិក្សាដែលបានធ្វើឡើងនៅខេត្តសៀមរាបសំរាប់អ្នកអនុវត្តគំរោង CBNRM ជាង ៣០ នាក់ នៅខែកក្កដា ឆ្នាំ ២០០១ ដើម្បីផ្តល់ជំនាញគ្រឹះសំរាប់ការសិក្សាស្រាវជ្រាវ PRA ការវិភាគពត៌មាន ការសរសេរអត្ថបទ និង ចងក្រងឯកសារ ។ ជាលទ្ធផល នៃតម្រូវការខ្ពស់សំរាប់ការងារប្រភេទនេះ វគ្គបណ្តុះបណ្តាលករណីសិក្សាមួយបានធ្វើឡើងនៅ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅខេត្តរតនៈគីរី ដែលមានអ្នកចូលរួមជាង ៤០ នាក់ ដើម្បីបង្កើនជំនាញខាងការស្រាវជ្រាវ និងជំនាញសរសេរអត្ថបទ ដើម្បីផ្តួចផ្តើមបង្កើតជាក្របខ័ណ្ឌការងារដែលជាទស្សនទានមួយសំរាប់ការងារ CBNRM នៅក្នុងប្រទេសកម្ពុជា ។ ជាលទ្ធផលបានមកពីការបណ្តុះបណ្តាលនេះ យើងបានរៀបចំផែនការការងារករណីសិក្សាមួយដែលមានបញ្ចូលទាំងការកំណត់ប្រធានបទ និងសេចក្តីព្រាងគំនិត ។

ករណីសិក្សានេះ គឺជាផ្នែកមួយនៃករណីសិក្សាចំនួន ១០ ធ្វើការផ្តោតទៅលើទាំងបញ្ហាជលផល និងបញ្ហាព្រៃឈើដែលបានបង្កើតឡើងនៅក្នុងភូមិសាស្ត្រសំខាន់ ៤ នៃប្រទេសកម្ពុជាដែលមាន តំបន់ខ្ពង់រាប (ខេតរតនៈគីរី និងមណ្ឌលគីរី ) តំបន់ទំនាបកណ្តាល (ខេត្តពោធិសាត់ និងកំពង់ឆ្នាំង ) តំបន់ទន្លេមេគង្គ ឬ ទន្លេសាប (ខេត្តស្ទឹងត្រែង និងសៀមរាប ) និងតំបន់ឆ្នេរ (ខេត្តកោះកុង និងកំពង់សោម) ។

តាមករណីជាច្រើនសេចក្តីព្រាងលើកទី ១ របស់ករណីសិក្សាទាំង១០ ត្រូវបានបង្កើតឡើងដោយក្រុមស្រាវជ្រាវ និងអ្នកនិពន្ធ ចម្រុះដោយចាប់ពី ខែ មករា ដល់ ខែ មេសា ឆ្នាំ ២០០២ ។ សេចក្តីព្រាងលើកទី ២ ត្រូវបានលើយកមកបង្ហាញដើម្បីទទួលយកនូវការផ្តល់យោបល់ក្នុងពេលធ្វើសិក្ខាសាលា និងសិក្ខាសាលាបូកសរុបដែលបានធ្វើនៅខេត្តកោះកុង ខែ ឧសភា ឆ្នាំ២០០២ ។ នៅពេលនោះ ករណីសិក្សាទាំងនេះត្រូវបានពិនិត្យមើលបកប្រែជាភាសាអង់គ្លេស ហើយបានធ្វើការកែសម្រួលដើម្បីបោះពុម្ព និងផ្សព្វផ្សាយ ។ អ្នកសម្របសម្រួលគំរោងនៅតាមមូលដ្ឋាន ដើរតួនាទីឈានមុខក្នុងការជ្រើសរើសប្រធានបទសម្រាប់ការសិក្សាស្រាជ្រាវ ការប្រមូលពត៌មាន និងការសរសេរអត្ថបទ ។ អ្នកសម្របសម្រួល និងទីប្រឹក្សាថ្នាក់ជាតិផ្តល់ជាជំនួយលើការពិនិត្យមើលគំរោងករណីសិក្សា ការវិភាគពត៌មាន ការបកប្រែ និងការកែសម្រួល ។

ដោយធ្វើការតាមគំនិតផ្តួចផ្តើមនេះ បានផ្តល់ឱ្យអ្នកចូលរួមក្នុងកម្រិតផ្សេងៗគ្នានូវឱកាសរៀនជំនាញបានកាន់តែច្រើនដើម្បីចែករំលែកបទពិសោធន៍ជាមួយគំរោង និងមនុស្សផ្សេងៗ ដែលធ្វើការខាងការងារ CBNRM នៅទូទាំងប្រទេសកម្ពុជា ។ តាមមធ្យោបាយបែបនេះ គំនិតផ្តួចផ្តើមចងក្រងករណីសិក្សា CBNRM ត្រូវបានគេប្រើជាឧបករណ៍មួយសម្រាប់បង្កើតជាបណ្តាញការងារ និងចែករំលែកមេរៀនដែលទទួលបាន។ ករណីសិក្សាទាំងនេះនឹងត្រូវបានគេចែករំលែកផងដែរ នៅតាមវេទិការនានាដូចជា សិក្ខាសាលា CBNRM ដែលនឹងធ្វើនៅខែ វិច្ឆិកា ឆ្នាំ ២០០២ ។ គេរំពឹងទុកថាលទ្ធផលនេះ នឹងត្រូវបានប្រើប្រាស់ ដើម្បីជាពត៌មានដល់ការបង្កើតគោលនយោបាយទៅថ្ងៃមុខនៅក្នុងប្រទេសកម្ពុជា ។

# មាតិកាអត្ថបទ

## កត្តាចាំបាច់ដែលសំខាន់ដែលជំរុញអោយអ្នកភូមិចូលរួមបង្កើតសហគមន៍នេសាទ និងការជួយពីអង្គការមិនមែនរដ្ឋាភិបាល


១. សេចក្តីផ្តើម ........ ១

២. ប្រវត្តិ ........ ១

ក. លក្ខណៈភូមិសាស្ត្រ ........ ១

ខ. អ្នកភូមិ និងជីវភាពរស់នៅ ........ ១

៣. មូលហេតុដែលនាំអោយសហគមន៍មូលដ្ឋានចូលរួមរៀបចំសហគមន៍នេសាទ ........ ២

ក. សកម្មភាពអនាធិបតេយ្យលើដែននេសាទ ........ ២

ខ. ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ........ ៤

ខ.១ -ខ្សែភ្លើងឆក់ ........ ៤

ខ.២ -គ្រឿងផ្ទុះ ........ ៥

គ. ផលប៉ះពាល់របស់ជីវភាពសហគមន៍មូលដ្ឋានដែលបណ្តាលមកពីធនធានត្រី និងវារីសត្វផ្សេងៗថយចុះ ........ ៥

ឃ. ជំលោះរវាងអ្នកនេសាទក្នុងភូមិ និងអ្នកនេសាទខាងក្រៅភូមិ ........ ៦

ង. ការយល់ឃើញរបស់សហគមន៍មូលដ្ឋានពីការនេសាទ ........ ៦

ច. កង្វះខាតនៃការគាំទ្រពីស្ថាប័នជំនាញ និងគោលនយោបាយ ........ ៦

ឆ. កិច្ចសហការ និងការគាំទ្ររបស់អង្គការ ........ ៧

៤. អត្ថប្រយោជន៍នៃការថែរក្សាសហគមន៍នេសាទដែលបានរៀបចំរួច ........ ៧

ក. បទល្មើសនេសាទថយចុះ ........ ៧

ខ. ការចូលរួមគ្រប់គ្រងសហគមន៍នេសាទដោយអ្នកភូមិ ........ ៨

៥. ភាពច្បាស់លាស់នៃតួនាទី និងចេតនាសន្តិនៃការគ្រប់គ្រងសហគមន៍នេសាទគុមិឡុងខ្លា និងអូរម្រះ ........ ៩

ក. -ប្រធានគណៈកម្មការសហគមន៍នេសាទ ........ ១០

ខ. -អនុប្រធានគណៈកម្មការ ........ ១០

គ. -ផ្នែកផ្សេងៗ ........ ១០

ឃ. -សមាជិកសហគមន៍នេសាទ ........ ១០

ង. -តួនាទីរបស់បុរស -ស្ត្រីចូលរួមក្នុងដំណើរការនៃសហគមន៍នេសាទ ........ ១០

៦. សិទ្ធិ និងការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋានលើធនធានជលផល ........ ១១

៧. ការបង្កើនចំណេះដឹង និងផ្សព្វផ្សាយព័ត៌មាននានាដល់សហគមន៍មូលដ្ឋាន ........ ១១

៨. សន្និដ្ឋាន ........ ១២

៩. អនុសាសន៍ ........ ១២

១០. ប្រវត្តិនៃគំរោងស្តីពី " អង្គការសហគមន៍ជំនួយបរទេស " ........ ១៤

១១. ប្រវត្តិនៃគំរោងករណីសិក្សាៈ " ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម " ........ ១៦

## កត្តាគន្លឹះសំខាន់ៗដែលជំរុញអោយអ្នកភូមិចូលរួមបង្កើតសហគមន៍នេសាទ និងការជួយថែរក្សាធនធានជលផល

### ១. សេចក្តីផ្តើម:

ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ជាកត្តាចាំបាច់សំរាប់ធានាបាននូវនិរន្តភាព ហើយជាប្រភពដ៏មានសារៈប្រយោជន៍យូរអង្វែងសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ពិសេស សំរាប់បងប្អូនជនជាតិភាគតិចដែលកំពុងបានរស់នៅក្នុងខេត្តស្ទឹងត្រែង ។ ជាក់ស្តែង ដូចជាការចូលរួមគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍នេសាទក្នុងពេលបច្ចុប្បន្ន ។

មានហេតុផលពីរយ៉ាងដែលជាអត្ថប្រយោជន៍សំរាប់ការរៀបចំសហគមន៍នេសាទ គឺថាប្រជាជនទាំងពីរភូមិនេះ ចូលរួមបង្កើតសហគមន៍នេសាទ ពីព្រោះវាជាចំនុចល្អ ជួយកាត់បន្ថយនូវការធ្លាក់ចុះនៃធនធានជលផលដែលបណ្តាលមកពីសកម្មភាពខុសច្បាប់ជាច្រើនទៅលើដែននេសាទក្នុងតំបន់នេះ ព្រមទាំងអាចជួយដោះស្រាយជំលោះរវាងអ្នកភូមិ និងអ្នកនេសាទខាងក្រៅ ក្នុងគោលបំណងជំរុញអោយធនធានមាននិរន្តភាពសំរាប់ពេលអនាគត ។ ដោយសារកង្វះខាត ការគ្រប់គ្រងពីស្ថាប័នច្បាប់ទេស លើដែននេសាទដែលនៅដាច់ស្រយាល គួបផ្សំគោលនយោបាយ វិស័យជលផលបានធ្វើអោយប្រជាជនចូលរួមក្នុងការរៀបចំសហគមន៍នេសាទ ។ម្យ៉ាងទៀត អ្នកភូមិអាចរៀបចំសហគមន៍នេសាទបាន គឺដោយសារការគាំទ្រ គួបផ្សំនិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងអង្គការ អូស៊ីអេអេ ជាមួយមន្ទីរកសិកម្មខេត្តស្ទឹងត្រែង ពិសេស ការិយាល័យជលផលបានជំរុញអោយមានការបង្កើតសហគមន៍នេសាទក្នុងភូមិនេះ ។

អត្ថប្រយោជន៍នៃការបង្កើតសហគមន៍នេសាទគឺ វាអាចជួយកាត់បន្ថយបទល្មើសនេសាទ បង្កើនការចូលរួមរបស់សហគមន៍ក្នុងដំណើរសហគមន៍នេសាទ ទាំងនារីស្ត្រី បុរសក្នុងការចូលរួមគ្រប់គ្រងធនធានជលផល កំណត់ពីសិទ្ធិនិងការទទួលខុសត្រូវលើធនធានបានយ៉ាងច្បាស់លាស់ ព្រមទាំងអាចជួយបង្កើនការយល់ដឹង និងទទួលបានចំណេះដឹងស្តីពីប្រព័ន្ធអេកូឡូស៊ីរួមជាមួយការគ្រប់គ្រងធនធានជលផល ។

### ២. ប្រវត្តិ

#### ក. លក្ខណៈភូមិសាស្ត្រ

ភូមិត្បូងខ្លា និងអូរម្រះជាតំបន់ភ្នំ និងខ្ពង់រាបដែលសំបូរដោយធនធានធម្មជាតិដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ដូចជា ព្រៃឈើ និងធនធានជលផល ។ លើសពីនេះ ភូមិនេះស្ថិតនៅតាមទន្លេមេគង្គមានលក្ខណៈអំណោយផលល្អដោយមានអន្លង់ជ្រៅៗ ថ្មរដិបរដុប កោះតូចៗ ព្រៃលិចទឹក ព្រមទាំងទឹកហូរយ៉ាងខ្លាំងនៅរដូវវស្សាដែលជាឧបសគ្គក្នុងការធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍សិប្បកម្មខ្លះ តែផ្ទុយទៅវិញវាមានលក្ខណៈយ៉ាងល្អប្រសើរសំរាប់ជាទីជំរករស់នៅ និងការពងកូនរបស់ពពួកមច្ឆាជាតិ និងវារីសត្វផ្សេងៗ ពិសេស ប្រភេទត្រីមេពូជសំខាន់ៗ។

#### ខ. អ្នកភូមិ និងជីវភាពរស់នៅ

ពីមួយឆ្នាំទៅមួយឆ្នាំ ដង់ស៊ីតេប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់ ដោយសារតែមានការអភិវឌ្ឍន៍នៅក្នុងតំបន់នេះ ហើយ ពួកគេរស់នៅតាមដងទន្លេមេគង្គ ដោយពឹងផ្អែកលើមុខរបរសំខាន់ ២ប្រភេទគឺ ធ្វើស្រែ និងការនេសាទ ។ ក្រៅពីសកម្មភាពនេះ ពួកគេបានទៅធ្វើចំការ និងប្រមូលអនុផលផ្សេងៗ ដូចជា ការប្រមាញ់សត្វ បន្លែផ្លែឈើព្រៃ រុក្ខជាតិជាឱសថ និងដាំបន្លែតាមដងទន្លេ សំរាប់តំរូវការផ្គត់ផ្គង់ជីវភាពបន្ថែម ។



ការធ្វើសំភាសន៍ជាមួយគណៈកម្មការសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន

ក្នុងចន្លោះឆ្នាំ១៩៦០-១៩៧០ ជារបបសង្គមរាស្ត្រនិយមភូមិត្បូងខ្លា និងអូរម្រះ គឺមានឈ្មោះតែមួយដែលហៅថា ភូមិជ្រោយស្លែង ។ ក្នុងជំនាន់នោះប្រជាជនភាគច្រើនជាជនជាតិភាគតិច ដែលគេហៅថាជនជាតិគួយ ។ ក្នុងកំឡុងឆ្នាំ១៩៧០-១៩៨០ ជារបបលន់ណុល និងប៉ុលពត ប្រជាជនមួយចំនួនក្នុងស្រុកបានផ្លាស់ប្តូរទីលំនៅពីតំបន់ផ្សេង ចូលមករស់នៅក្នុងទីកន្លែងនេះ បន្ទាប់មកតំបន់នេះ ត្រូវបានចែកជាពីរភូមិ គឺភូមិអូរម្រះ និងត្បូងខ្លា ដែលស្ថិតនៅឃុំអូរម្រះស្រុកសៀមបូក។ វាមានចំងាយប្រមាណ ៥៨ គីឡូម៉ែត្រ ពីទីរួមខេត្តស្ទឹងត្រែង ។

បច្ចុប្បន្ន ភូមិពីរនេះមានព្រំប្រទល់រដ្ឋបាលជាប់គ្នា ប្រជាពលរដ្ឋមានសរុបចំនួន ១៥២គ្រួសារ មានដើមកំណើតពីជនជាតិគួយ និងខ្មែរ។ ចំពោះសហគមន៍នេសាទត្បូងខ្លាមានប្រជាជនសរុបចំនួន ១៣៤គ្រួសារ ក្នុងនោះខ្មែរប្រមាណ ៨០គ្រួសារ និង ៥៤គ្រួសារ ជាជនជាតិគួយ និងសហគមន៍នេសាទអូរម្រះមានចំនួន ១៨គ្រួសារ ដែលមានជនជាតិខ្មែរប្រមាណ ១០គ្រួសារ ព្រមទាំងជនជាតិគួយចំនួន ៨គ្រួសារ។ ប្រជាជនក្នុងពីរភូមិប្រមាណ ៩០ភាគរយ ពឹងផ្អែកលើស្រែ-ចំការ និងនេសាទជាមុខរបរចំបង ហើយប្រហែល ១០ភាគរយ ជាអ្នកលក់ដូរ និងជាឈ្មួញ ។

## ៣. មូលហេតុដែលនាំអោយសហគមន៍មូលដ្ឋានចូលរួមរៀបចំសហគមន៍នេសាទ

### ក. សកម្មភាពអនាធិបតេយ្យលើដែននេសាទ

ក្នុងកំឡុងឆ្នាំ១៩៨៤ ដល់ ១៩៩៨ បទល្មើសនេសាទតែងតែកើតឡើងជាញឹកញាប់លើដែននេសាទនៃភូមិអូរម្រះ និងត្បូងខ្លា ដើម្បីធ្វើនេសាទប្រភេទត្រីដែលមានតំលៃសេដ្ឋកិច្ច និងប្រភេទសត្វល្មូនសំខាន់។ ការនេសាទក្នុងតំបន់នេះ សំរាប់អ្នកភូមិខ្លះបានប្រើប្រាស់ឧបករណ៍លក្ខណៈសិប្បកម្ម ក្នុងការនេសាទនៅរដូវបិតនេសាទ ដោយពុំទាន់បានយល់ច្បាស់លាស់អំពីច្បាប់ជលផល។ លើសពីនេះទៀត អ្នកនេសាទខាងក្រៅបានចូលមកតំបន់នេះ ធ្វើនេសាទដោយឧបករណ៍ហាមឃាត់ដូចជា ការប្រើរំសេវផ្ទុះ ថ្នាំបំពុល គ្រាប់បែក ចរន្តអគ្គិសនី ពីព្រោះថា វាចំណាយដើមទុនតិច ហើយងាយស្រួលប្រមូលផលត្រីបានច្រើនលើសលប់នៅពេលរដូវប្រាំង ពិសេស ប្រភេទត្រីភាគ ច្រើនបានប្រមូលផ្តុំគ្នាក្នុងអន្លង់ធំៗ។

# ផែនទីៈ ករណីសិក្សាស្រាវជ្រាវនៅឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង



ទន្ទឹមនឹងនោះផងដែរ សហគមន៍មូលដ្ឋានខ្លះបានប្រើប្រាស់គ្រឿងផ្ទុះ ព្រមទាំងបានចំលងយកវិធីសាស្ត្រ ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ពីអ្នកខាងក្រៅ ទាំងនេះជា សកម្មភាពអណាធិតេយ្យដែលកំពុងបានគំរាមកំហែងយ៉ាងខ្លាំងក្លាដល់ជីវចំរុះជលផល។ លើសពីនេះទៀត តំរូវការទីផ្សារនាំចេញនូវប្រភេទត្រីដែលមានតំលៃសេដ្ឋកិច្ចទៅកាន់ប្រទេសឡាវ និងថៃ បានធ្វើអោយឈ្មួញចូលមកតំបន់នេះ ហើយពួកគេបានឆ្លៀតឱកាសផ្តល់ឧបករណ៍ល្មើសច្បាប់ដល់ អ្នកនេសាទខាងក្រៅ និងសហគមន៍មូលដ្ឋានខ្លះ បន្ទាប់មក ពួកគេរង់ចាំប្រមូលទិញផលនេសាទ ពីអ្នកទាំងនោះវិញ និងអ្នកនេសាទផ្សេងទៀត ដើម្បីដឹកជញ្ជូនផលត្រីទាំងនោះទៅប្រទេសក្រៅ។ ជាងនេះ អ្នកភូមិស្ទើរតែទាំងអស់ បាននាំគ្នាដាំបន្លែនៅតាមច្រាំងមាត់ទន្លេ ដោយបានកាប់ព្រៃលិចទឹកដែលដុះតាមច្រាំងទន្លេ ព្រមទាំងបានបណ្តាលអោយបាត់បង់ប្រភពចំណី និងជំរកសំរាប់ត្រីពងកូន។ ក្នុងកំឡុងពេលដដែលនោះ មានក្រុមហ៊ុនមួយកាប់ឈើហ៊ុបបានប្រមូលយកឈើរាប់រយដើមចេញពីព្រៃ ដើម្បីស្តុបទុកក្បែរអន្លង់ថ្មធំ និងបរិមាណឈើមួយចំណែកត្រូវបានទំលាក់ក្នុងអន្លង់ទន្លេនេះ ដើម្បីរង់ចាំការដឹកជញ្ជូនចេញទៅកន្លែងផ្សេងតាមផ្លូវទឹក។ អន្លង់នេះជាទីជំរកសំខាន់របស់ត្រី និងវារីសត្វផ្សេងៗដែលបណ្តាលអោយប្រភេទត្រីភាគច្រើនធ្វើចរាចរទៅកាន់តំបន់ផ្សេង ដោយហេតុថាសំបកឈើហ៊ុបជាច្រើនបានធ្វើប្រតិកម្មជាមួយទឹក ហើយបញ្ចេញសារធាតុចូលទៅក្នុងទឹកវិញ ពិសេស កូនត្រីតូចជាច្រើនត្រូវបានស្លាប់។ ដោយឡែក សត្វផ្សោតដែលជាសោភណ្ឌភាពមួយសំរាប់ទាក់ទាញភ្ញៀវទេសចរ តែពួកវាទាំងអស់បានផ្លាស់ប្តូរទៅកាន់តំបន់ផ្សេង។

> នៅពេលថ្មី មានអ្នកនេសាទវៀតណាមបានចូលមកដល់តំបន់នេះ ហើយធ្វើការនេសាទដោយប្រើប្រាស់ឧបករណ៍ឡូក និងអំពូលមួយ រួមផ្សំជាមួយអាគុយមួយកំលាំង ១២វ៉ុល។ សកម្មភាពនេសាទនេះ កំពុងបានគំរាមកំហែងដល់ប្រភេទត្រីមេពូជ ព្រមទាំងបានបង្កអោយមានផលប៉ះពាល់ជា អវិជ្ជមានដល់ជីវភាពរស់នៅនៃសហគមន៍មូលដ្ឋាន។ លោក ផាន់ វ៉ាន់ឌី អាយុ ៣៥ ឆ្នាំ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២។

ដូច្នេះ សកម្មភាពទាំងនេះសុទ្ធតែមានភាពអណាធិបតេយ្យដែលជាមូលហេតុបណ្តាលអោយគ្រោះថ្នាក់ដល់ប្រភេទត្រីមេពូជ សត្វល្មូន និងវារីសត្វផ្សេងៗ ដែលមាននៅក្នុងទន្លេនេះ។

## ខ. ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់

### ខ.១ -ខ្សែភ្លើងឆក់

វាជាប្រភេទឧបករណ៍ដែលរួមផ្សំឡើងដោយអាគុយ ០១ ឬ ០២ គ្រឿង ហើយមានកំលាំងចាប់ពី ១២ វ៉ុលឡើងទៅ និងមានខ្សែភ្លើងស្ថិតនៅស្របជងឬស្សីភ្ជាប់នឹងកញ្ច្រែងដែក និងមានកុងតាក់សំរាប់បើកបិត។ ឧបករណ៍នេះមានរូបរាងខុសៗគ្នាគឺអាស្រ័យតាមការសាងសង់របស់អ្នកនេសាទ ហើយវាងាយស្រួលផ្គុំបញ្ចូល និងបំបែកចេញពីគ្នាដែលអាចធ្វើនេសាទប្រមូលបានទិន្នផលប្រភេទត្រីធំៗ ហើយគេប្រើប្រាស់វានៅគ្រប់ទីកន្លែងលើដែននេសាទដូចជា តាមមាត់ព្រែក អូរ អន្លង់ និងទន្លេ។ លើសពីនេះ នៅពេលអ្នកនេសាទកំពុងប្រើប្រាស់លើដែននេសាទបាននាំអោយប្រភេទត្រី និងវារីសត្វផ្សេងៗ ដែលស្ថិតក្នុងរង្វង់ដែន

ជំនាញត្រូវស្លាប់មួយភាគធំ ពិសេសប្រភេទត្រីមេពូជដែលមិនទាន់ត្រូវខូចកន្សោមពង និងប្រពន្ធ័សរីរាង្គមួយចំនួនត្រូវខូចខាតទាំងស្រុងផងដែរ។

១.២ -គ្រឿងផ្ទុះ

គ្រឿងផ្ទុះរួមមាន គ្រាប់បែក និងការផ្សំម្សៅជាតិផ្ទុះ នៅពេលដែលប្រើប្រាស់វាលើដែននេសាទគឺ មានកំលាំងយ៉ាងខ្លាំងក្លា មិនត្រឹមតែប៉ះពាល់ដល់ប្រភេទត្រីប៉ុណ្ណោះទេ សូម្បីតែមនុស្សក៏អាចធ្វើអោយបាត់បង់ជីវិតផងដែរ ។ លើសពីនេះទៀត វាបានបង្ក ឥទ្ធិពលយ៉ាងអាក្រក់ដល់អេកូឡូស៊ីរបស់វារីជីវចំរុះ ។ គេអាចធ្វើការប្រើប្រាស់គ្រឿងផ្ទុះនេះបានគ្រប់ទីកន្លែង ។

**៣. ផលប៉ះពាល់ចំពោះជីវភាពសហគមន៍មូលដ្ឋានដែលបណ្តាលមកពីធនធានត្រី និងវារីសត្វផ្សេងៗថយចុះ**

ក្នុងកំឡុងឆ្នាំ ១៩៨០ ដល់ ១៩៨៤ ប្រជាជនក្នុងភូមិទាំងពីរធ្វើស្រែ គឺគ្រាន់តែសំរាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃប៉ុណ្ណោះ។ ប៉ុន្តែការនេសាទវិញ ពួកគាត់អាចប្រមូលផលត្រីបានល្អប្រសើរ ព្រមទាំងអាចរកចំណូលពីការធ្វើនេសាទនេះ ដើម្បីជួយដោះស្រាយនូវសំភារៈសំរាប់ប្រើប្រាស់ក្នុងគ្រួសារ ដោយហេតុថា ក្នុងពេលនោះពុំទាន់មានអ្នកខាងក្រៅប្រើប្រាស់ឧបករណ៍ទំនើបៗ។ ឧទាហរណ៍ គ្រួសារនិមួយៗនៅក្នុងភូមិនេះ បានប្រើប្រាស់ឧបករណ៍មងដែលមានប្រវែង ៥០ម៉ែត្រ ដើម្បីធ្វើនេសាទដោយទទួលផល



សកម្មភាព និងការប្រើប្រាស់ឧបករណ៍នេសាទ

ត្រីពី ៦-១០គីឡូក្រាមក្នុងមួយថ្ងៃ ហើយជីវភាពរបស់អ្នកភូមិពេល នោះមានលក្ខណៈល្អបង្គួរ។ ក្រោយមកក្នុងឆ្នាំ ១៩៨៤ ដល់ ១៩៩៨ អ្នកភូមិភាគច្រើន ពុំអាចរកចំណូលពីការធ្វើនេសាទដោយសារ ការប្រមូលទិន្នផលត្រីបានតិចតួចបំផុតសំរាប់តែផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារប្រចាំថ្ងៃប៉ុណ្ណោះ។ ជាពិសេស គ្រួសារខ្លះដែលមាន ត្រឹមតែឧបករណ៍សំណាញ់ និងលប តែគ្មានមងដែលធ្វើអោយពួកគាត់ពុំអាចចាប់ត្រីសំរាប់ប្រើប្រាស់ជាម្ហូបអាហារ។ ដូចនេះ បណ្តាលអោយពួកគាត់ជួបប្រទះនូវការលំបាកយ៉ាងខ្លាំងក្នុងដំណើរការរស់នៅ ព្រមទាំងធ្វើអោយជីវភាពនៃសហគមន៍មូលដ្ឋានស្ថិតក្នុងសភាពខ្សត់ខ្សោយ ទាំងនេះពីព្រោះអ្នកនេសាទខាងក្រៅបានប្រើប្រាស់ឧបករណ៍ហាមឃាត់ គួបផ្សំជាមួយសកម្មភាពនេសាទបិទអូរ និងព្រៃកបានធ្វើអោយជះឥទ្ធិពលអវិជ្ជមានដល់ប្រភេទវារីជីវចំរុះជលផល ពីព្រោះថាមិនត្រឹមតែការនេសាទយកប្រភេទត្រីធំៗ និងសត្វល្អនប៉ុណ្ណោះទេ សូម្បីតែប្រភេទត្រីតូចៗ ក៏ពួកគេប្រមូលយកគ្មានសល់។

ដោយជួបបញ្ហានេះ ប្រជាជនមួយចំនួនដែលមានលទ្ធភាពបានបង្វិចិត្តបង្កើនការប្រើប្រាស់មងដែលមានប្រវែង ២០០-២៥០ម៉ែត្រក្នុងមួយគ្រួសារ ហើយបរិមាណត្រីដែលចាប់មានកំរិតទាបគឺ ១-២គីឡូក្រាមក្នុងមួយថ្ងៃ។ ម្យ៉ាងទៀត សមត្ថកិច្ចជំនាញពាក់ពន្ធ័ពុំបានត្រួតពិនិត្យក្នុងតំបន់ជាប្រចាំផងនោះ បានធ្វើអោយការនេសាទមានវិសាលភាពធំធេងហួសពីលទ្ធភាពផ្តល់អោយ ជាហេតុធ្វើអោយផលស្តុកត្រីក្នុងធម្មជាតិ កំពុងត្រូវបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។

ដូច្នេះ វាជាចំណុច សំខាន់ក្នុងពេលដែលធនធានត្រី និងវារីសត្វផ្សេងៗត្រូវបានថយចុះ ហើយនាំអោយមានការជះឥទ្ធិពលយ៉ាងអាក្រក់ដល់ជីវភាពរស់នៅនៃសហគមន៍មូលដ្ឋាន ពិសេស កូនចៅជំនាន់ក្រោយរបស់ពួកគាត់នឹងជួបប្រទះនូវភាពក្រីក្រដដែល ។

### ឃ. ទំនាស់រវាងអ្នកនេសាទក្នុងភូមិ និងអ្នកនេសាទខាងក្រៅភូមិ

ជាញឹកញាយក្នុងតំបន់នេសាទនេះ ទំនាស់តែងតែកើតឡើងពីការធ្វើអាជីវកម្មដោយឧបករណ៍នេសាទខុសច្បាប់ និងការប្រកួតប្រជែងនៃការនេសាទ ក្នុងគោលបំណងទាញយកផលប្រយោជន៍ដ៏លើសលប់ពីធនធានជលផលតាមមធ្យោបាយរៀងៗខ្លួន។ ចំពោះការធ្វើនេសាទរបៀបនេះ ត្រូវបានកើតចេញជាទំនាស់ខ្លះៗរវាងអ្នកនេសាទក្នុងភូមិ ប៉ុន្តែ ទំនាស់នេះមានលក្ខណៈស្រាលនៅឡើយ ព្រមទាំងអាចដោះស្រាយបានទៀតផង។ ជាពិសេស អ្នកនេសាទខាងក្រៅច្រើនតែពុំគោរពច្បាប់ជលផលគួបផ្សំនិងអ្នកមានអំណាចការពារពួកគេផង បានធ្វើអោយកើតចេញជាជំលោះជាមួយអ្នកនេសាទក្នុងភូមិ ហើយជំលោះនេសាទប្រភេទនេះ ច្រើនមានសភាពតានតឹងរហូតដល់ធ្វើការប្តឹងផ្តល់គ្នាទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលដែលប្រចាំការនៅមូលដ្ឋាន។ ទោះបីជាមានការប្តឹងផ្តល់ក្តីក៏ជំលោះនេះពិបាកនឹងរកដំណោះស្រាយឃើញតាមបែបយុត្តិធម៌ ពីព្រោះថាសហគមន៍មូលដ្ឋាន ភាគច្រើនត្រូវបានគេបៀតបៀន និងគំរាមគំហែងពីសណាក់ល្មើសជនប្រដាប់អាវុធ និងអ្នកមានអំណាច ។

### ង. ការយល់ឃើញរបស់សហគមន៍មូលដ្ឋានពីការនេសាទ

ដោយសារតែជួបប្រទះនូវការលំបាកក្នុងការនេសាទ និងការមើលឃើញពីការបាត់បង់យ៉ាងធ្ងន់ធ្ងរនូវធនធានធម្មជាតិ ពិសេសធនធានជលផលនៅក្នុងតំបន់នេះ ត្រូវបានធ្វើការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដែលបណ្តាលអោយវារីជីវចំរុះក្នុងធម្មជាតិត្រូវទទួលរងនូវការបំផ្លាញយ៉ាងលើសលប់ បានធ្វើអោយអ្នកភូមិភាគច្រើនមានសុទ្ធន្ទ:ចង់ធ្វើការអភិរក្សនូវធនធានជលផលក្នុងតំបន់នេះ ពីព្រោះថាតាមរយៈនៃការការពារធនធានដោយផ្ទាល់ វាអាចជួយដល់ការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយនិរន្តភាព។

### ច. កង្វះខាតនៃការគាំទ្រពីស្ថាប័នជំនាញ និងគោលនយោបាយ

ក្នុងកំឡុងឆ្នាំ១៩៨២ ដល់១៩៩៣ ក្នុងខេត្តស្ទឹងត្រែងនេះការងារជលផល និងរុក្ខាប្រមាញ់ត្រូវបានបញ្ចូលជាការិយាល័យតែមួយ ពីព្រោះថា ពុំទាន់មានមន្ត្រីបច្ចេកទេសគ្រប់គ្រាន់ ដើម្បីទទួលបន្ទុកលើការងារនេះ។ នៅចុងឆ្នាំ១៩៩៣ យោងសេក្តីសំរេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការិយាល័យនេះត្រូវបានបំបែកជា ០២ ដើម្បីធ្វើការទៅតាមជំនាញរៀងៗខ្លួន។ ពេលនោះ សមត្ថកិច្ចជំនាញជលផលក៏ពុំទាន់អាចបង្ក្រាបបទល្មើសនេសាទនៅតំបន់នេះបានឡើយ ដោយហេតុថាសកម្មភាពបទល្មើសនេះត្រូវបានការពារពីកងប្រដាប់អាវុធ និងអ្នកមានអំណាចចូលរួម។ ជាមួយគ្នានេះដែរ កិច្ចសហការរបស់អាជ្ញាធរមូលដ្ឋានជាមួយនិងជំនាញ ដើម្បីទប់ស្កាត់បទល្មើសនេសាទនៅមានកំរិត។ ទន្ទឹមនឹងនោះដែរ គោលនយោបាយនៃរាជរដ្ឋាភិបាលពុំទាន់បានធ្វើការកែទំរង់របស់ខ្លួននៅឡើយ ដែលនាំអោយស្ថាប័នបច្ចេកទេសដែលជាសេនាធិការផ្ទាល់ ក៏ពុំទាន់ហ៊ានធ្វើសេចក្តីសំរេចចិត្តលើកំណែទំរង់នៃវិស័យរបស់ខ្លួនដែរ ។

ទំលាប់ទាំងនេះ ជាកង្វះខាតមួយដ៏ធំ ព្រមទាំងផ្តល់ភាពលំបាកយ៉ាងខ្លាំងដល់ប្រជាជននៅតាមតំបន់ជនបទដែលរស់នៅដោយពឹងផ្អែកលើធនធានធម្មជាតិទាំងស្រុង តែផ្ទុយទៅវិញ បានធ្វើអោយជនល្មើសងាយស្រួលឆ្លៀតឱកាសក្នុងការទាញយកផលប្រយោជន៍ពីធនធានជលផលនេះ។

**ខ. កិច្ចសហការ និងការគាំទ្ររបស់អង្គការ**

នៅពេលដែលបានជួបប្រទះនូវសកម្មភាពបំផ្លាញធនធានជលផលក្នុងតំបន់នេះ ការិយាល័យជំនាញបានពុះពារគ្រប់សកម្មភាពបែបយ៉ាងក្នុងការធ្វើសេចក្តីសំរេចចិត្តសហការជាមួយអង្គការ អូស៊ីអេអេ ដែលជាអង្គការអូស្ត្រាលី បានអនុវត្តលើផ្នែកធនាគារស្រូវ ផ្នែកសុខភាពសត្វ ពិសេស កម្មវិធីរៀបចំសហគមន៍នេសាទ។ ទោះបីជា នាយកដ្ឋានជលផលពុំទាន់បានរៀបចំនិងបង្កើតចេញជាអនុក្រឹត្យក៏ដោយ ការិយាល័យជលផលបានបញ្ជូនមន្ត្រីចូលរួមការងារនេះនៅឆ្នាំ ១៩៩៨ ក្នុងគោលបំណងបំផុសអោយសហគមន៍មូលដ្ឋានយល់ពីតំលៃនៃធនធានជលផល និងធានាបាននូវការប្រើប្រាស់ប្រកបដោយនិរន្តភាពនៃជីវចំរុះជលផល។ បន្ទាប់មកដំណើរការនៃការរៀបចំសហគមន៍នេសាទត្រូវបានអនុវត្តឡើងនៅក្នុងតំបន់នេះ អាស្រ័យទៅតាមយុទ្ធសាស្ត្រ ព្រមទាំងការសំរបសំរួលពីអង្គការ អូស៊ីអេអេ។ ទោះបីជា មានការរៀបចំបង្កើតសហគមន៍រួចក្តីក៏អង្គការ អូស៊ីអេអេ នៅតែគាំទ្រនិងបន្តធ្វើការសំរបសំរួលរាល់បញ្ហាផ្សេងៗ ដែលនឹងអាចកើតមានជុំវិញសហគមន៍ដែលកំពុងបានចាប់ផ្តើមដំណើរការ។ ទន្ទឹមនឹងនោះដែរ អង្គការ អូស៊ីអេអេ បានខិតខំប្រឹងប្រែងជួយឧបត្ថម្ភជាសំភារៈ ថវិកា ស្មារតី ព្រមទាំងកិច្ចសហការយ៉ាងល្អប្រសើររវាងអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ពន្ធ័ ការិយាល័យជលផល និងអាជ្ញាធរដែនដីក្នុងការរៀបចំដំណើរការសហគមន៍នេសាទ។ ដូចនេះ តាមរយៈបណ្តាញការងារនេះ អាចជួយជំរុញសហគមន៍មូលដ្ឋានយល់ដឹងពីគោលការណ៍អភិរក្ស និងការគ្រប់គ្រងធនធានជលផលបានសមស្រប ហើយនឹងអាចជៀសវាងនូវភាពមហន្តរាយដល់ធនធានទាំងនេះ។ ម្យ៉ាងទៀត អង្គការនេះកំពុងបានកសាងសមត្ថភាពមន្ត្រីការិយាជំនាញសំរាប់ការសំរបសំរួលក្នុងសហគមន៍នេសាទ ព្រមទាំងបានពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋានដោយបានបើកវគ្គបណ្តុះបណ្តាលដល់គណៈកម្មការសហគមន៍ និងសមាជិកសំខាន់ៗ និងបានបញ្ជូនពួកគាត់ទៅចូលរួមវគ្គបណ្តុះបណ្តាល និងធ្វើទស្សនកិច្ចនៅតំបន់ផ្សេងក៏ដូចជាប្រទេសជិតខាង ដើម្បីអោយពួកគាត់ទទួលបានបទពិសោធន៍សំរាប់ធ្វើការអភិវឌ្ឍន៍សហគមន៍នេសាទបានប្រសើរឡើង។

## ៤. អត្ថប្រយោជន៍នៃការថែរក្សាសហគមន៍នេសាទដែលបានរៀបចំរួច

**ក. បទល្មើសនេសាទថយចុះ**

គោលបំណងនៃការរៀបចំសហគមន៍នេសាទ គឺដើម្បីជួយកាត់បន្ថយបទល្មើសនេសាទ និងការផ្តល់អំណាចដល់សហគមន៍មូលដ្ឋានក្នុងការរៀបចំគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលដោយខ្លួនឯង។ ពេលថ្មីៗនេះ មានអ្នកនេសាទវៀតណាម ២-៣នាក់ ដែលមកពីតំបន់ទំនាបកណ្តាលដោយបានប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជា ខ្សែភ្លើងឆក់ រួមផ្សំជាមួយអំពូល និងច្បូក ព្រមទាំងអាគុយមានកំលាំង ១២វ៉ុលដែលជាឧបករណ៍នេសាទទំនើប ហើយពួកគេបានធ្វើនេសាទនៅត្រង់អន្លង់កោះរៃជ័រ ។ សកម្មភាពនេសាទខុសច្បាប់នេះ ត្រូវបានបង្ក្រាបដោយអ្នកភូមិ ។ ទោះបីជា មានការខិតខំប្រឹងប្រែងការពារពីសហគមន៍មូលដ្ឋានក្តី ក៏ចំណេះដឹងរបស់ពួកគាត់នៅមានកំរិតលើការវិភាគនូវឧបករណ៍បទល្មើស ឧទាហរណ៍ជនល្មើសបាន

ប្រើប្រាស់អំពូលដែលមានលាយជាតិគីមី ហើយពន្លឺរបស់វាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទាក់ទាញប្រភេទត្រីជាច្រើន អោយមកក្បែរទូកនេសាទ។ លើសពីនេះ ការបន្តសាងសង់ឧបករណ៍នេសាទកាន់តែទំនើបៗ ព្រមទាំងអ្នកមានអំណាច និងវត្តមានជនប្រដាប់អាវុធចូលរួមការពារបទល្មើសនេសាទ ។ ដោយឡែក ទោះបីជា សហគមន៍នេសាទនេះមានលក្ខន្តិកៈកំណត់យ៉ាងច្បាស់លាស់ ក៏អ្នកភូមិតិចតួចនៅតែឆ្លៀតឱកាសប្រើប្រាស់ឧបករណ៍ហាមឃាត់ ដើម្បីរកប្រយោជន៍ផ្ទាល់ខ្លួន ។ ទោះបីតែ សហគមន៍នេសាទនេះនៅមានបញ្ហាតិចតួចពិតមែន ក៏អ្នកភូមិស្ទើរតែទាំងអស់ ព្យាយាមស្វែងរកដំណោះស្រាយរាល់សកម្មភាពស្មុគស្មាញ ដែលបានកើតឡើងរហូតដល់បទល្មើសនេសាទជាច្រើន ត្រូវបានកាត់បន្ថយជាបន្តើរៗ។

ក្នុងកំឡុងឆ្នាំ ១៩៨៥ដល់ ១៩៩៧ អ្នកខាងក្រៅ និងជនប្រដាប់អាវុធ បានប្រើប្រាស់ឧបករណ៍នេសាទ ខុសច្បាប់សំរាប់ចាប់ត្រីក្នុងអន្លង់កោះវៃជាំ និងអន្លង់ថ្មធំ។ ពួកគេបានបោកគ្រាប់បែកពី ០៥-១០គ្រាប់ក្នុងមួយថ្ងៃនៅក្នុងអន្លង់ ទាំងនេះ។ ការនេសាទបែបអណាធិបតេយ្យនេះ បានបណ្តាលអោយ ហ្វូងកូនត្រីជាច្រើនត្រូវបំផ្លាញ។ ទោះជាយ៉ាងនេះក្តី បទល្មើសនេសាទ ត្រូវបានកាត់បន្ថយបានមួយចំនួនធំ ក្រោយពីបានរៀបចំបង្កើតសហគមន៍នេសាទរួច។ លោក ផាន់ វុទ្ធី អាយុ ៣៨ឆ្នាំ .១៣ ០២. ២០០២។

## ខ. ការចូលរួមគ្រប់គ្រងសហគមន៍នេសាទដោយអ្នកភូមិ

ពីអតីតកាល តំបន់នេសាទនេះត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នជំនាញនៃរដ្ឋាភិបាល តែក្រោយពីការរៀបចំបង្កើតសហគមន៍នេសាទមក វាត្រូវបានប្រើប្រាស់ និងគ្រប់គ្រងដោយសហគមន៍មូលដ្ឋានផ្ទាល់ ។ អ្នកភូមិស្ទើរតែទាំងអស់ បានចូលរួមក្នុងដំណើរការនេះយ៉ាងសកម្ម ពីព្រោះថា ពួកគាត់មិនចង់ឃើញការរីកដុះដាលនូវសកម្មភាពបំផ្លិចបំផ្លាញធនធានត្រី និងវារីសត្វផ្សេងៗ ពីសំណាក់អ្នកនេសាទខាងក្រៅ និងអ្នកមានអំណាចការពារជនល្មើស ។ ម្យ៉ាងវិញទៀត ពួកគាត់មានការពេញចិត្តយ៉ាងខ្លាំង ដោយ បានធ្វើការបែងចែកទុកដែននេសាទសំរាប់នេសាទ ជាលក្ខណៈគ្រួសារ និងអន្លង់សំរាប់ធ្វើការអភិរក្សប្រភេទពូជត្រីសំខាន់ ។



ផលិតផលត្រីក្រោយពីការបង្កើតសហគមន៍

ចំពោះប្រភេទឧបករណ៍នេសាទ ត្រូវបានកំណត់ស្របតាមទីតាំងភូមិសាស្ត្រនៃដែននេសាទ ហើយមានការឯកភាពពីសហគមន៍មូលដ្ឋានទាំងអស់ ព្រមទាំងលក្ខន្តិកៈដែលបានកំណត់យ៉ាងច្បាស់លាស់ពីតួនាទីរបស់សមាជិកសហគមន៍នេសាទ និងបំរាមនានាសំរាប់ទប់ស្កាត់ភាពអណាធិបតេយ្យនេសាទ។ ពិសេស វាជាឱកាសដ៏ល្អបំផុតសំរាប់ពួកគាត់ បានធ្វើសេចក្តីសំរេចចិត្តខ្លួនឯង ដើម្បីទទួលខុសត្រូវនិងធ្វើការអភិរក្សលើធនធាននេះរួមគ្នាដោយហេតុថា ពីពេលមុនអ្នកភូមិមិនដែលធ្លាប់ទទួល

សិទ្ធិអំណាចចូលរួមគ្រប់គ្រង និងប្រើប្រាស់លើធនធានជលផល ព្រមទាំងបានទទួលនូវការបែងចែកផលប្រយោជន៍ ប្រកបដោយសមធម៌ ដែលស្របទៅតាមគោលនយោបាយបែបវិមជ្ឈការបច្ចុប្បន្ននេះឡើយ ។

អ្នកភូមិទាំងអស់ បានធ្វើសេចក្តីសំរេចចិត្តយកផ្ទៃដែននេសាទនៃអន្លង់ថ្មធំ និងអន្លង់កោះវៃជាមួយផ្នែក សំរាប់ធ្វើការអភិរក្ស វារីជីវចំរុះជលផល។ ពិសេស អន្លង់ថ្មធំដែលសំបូរសត្វផ្សោត។ ម្យ៉ាងវិញទៀត វានឹងអាចក្លាយជារមណីយដ្ឋានទេសចរណ៍ប្រណិត មួយក្នុងពេលអនាគត។ លោក គង់ វង អាយុ ៥៤ឆ្នាំ, ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០០២

យ៉ាងណាមិញ មិនត្រឹមតែសហគមន៍មូលដ្ឋានប៉ុណ្ណោះទេ សូម្បីមន្ត្រីស្ថាប័នជំនាញនៃរដ្ឋាភិបាលក៏នៅមានកង្វះខាតនូវចំណេះដឹង និងបទពិសោធន៍ខ្លះក្នុងដំណើរការរៀបចំផែនការ និងការគ្រប់គ្រងធនធានធម្មជាតិផងដែរ ។ ទោះបីជាមាន ចំណុចខ្វះខាតយ៉ាងនេះពិតមែន ក៏សហគមន៍នេសាទនេះមានមន្ត្រីសំរបសំរួលគំរោងដែលមានបទពិសោធន៍បាននៅប្រចាំការក្នុងតំបន់ផ្ទាល់ ព្រមទាំងការផ្តល់បច្ចេកទេសពីការិយាល័យជលផល ដើម្បីជំរុញអោយដំណើរការចូលរួមគ្រប់គ្រងរបស់សហគមន៍នេសាទ ដោយអ្នកភូមិនេះមានលក្ខណៈយ៉ាងល្អប្រសើរ ។

### ៥. តារាងច្បាស់លាស់នៃតួនាទី និងរចនាសម្ព័ន្ធនៃការគ្រប់គ្រងសហគមន៍នេសាទភូមិស្ទុងខ្លា និងអូរក្រះ

គណៈកម្មការសហគមន៍នេសាទ ជាផ្នែកមួយនៃគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ហើយត្រូវបានបង្កើតឡើងតាមការបោះឆ្នោតជ្រើសរើសគណៈកម្មការ មានភារៈកិច្ចគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។ ខាងក្រោមនេះ ជាគំនូសបំព្រួញនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍នេសាទ :



### ក. -ប្រធានគណៈកម្មការសហគមន៍នេសាទ

ប្រធានគណៈកម្មការសហគមន៍នេសាទ គឺជាអ្នកដឹកនាំ និងទទួលបន្ទុកលើការរៀបចំចងក្រងលក្ខន្តិកៈ និងធ្វើផែនការសំរាប់អនុវត្តការងារ ។ ជាងនេះ គណៈកម្មការមានភារកិច្ចត្រួតពិនិត្យវាយតំលៃលើការងារដែលអនុវត្តបានរួមមានទាំងការប្រជុំបណ្តុះបណ្តាលការងារ ធ្វើការទំនាក់ទំនងជាមួយស្ថាប័នជំនាញពាក់ពន្ធ័ អាជ្ញាធរដែនដី និងអង្គការជាតិ។ ក្នុងនោះផងដែរ គណៈកម្មការមានភារកិច្ចត្រួតពិនិត្យលើការគ្រប់គ្រង និងការប្រើប្រាស់រាល់ឧបករណ៍នេសាទ ព្រមទាំងបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។ លើសពីនេះទៀត ថ្នាក់ដឹកនាំត្រូវតែផ្សព្វផ្សាយបទដ្ឋានគតិយុត្តនានាដែលទាក់ទង និងចូលរួមគ្រប់គ្រងធនធានជលផល ដើម្បីអោយសមាជិកសហគមន៍យល់បានច្បាស់លាស់ ពិសេស ត្រូវចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយជំលោះនេសាទ ដែលបានកើតឡើង ក្នុងករណីយពុំអាចដោះស្រាយបានទេ ពួកគាត់ធ្វើកំណត់ហេតុបញ្ជូនទៅអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញ។

### ខ. -អនុប្រធានគណៈកម្មការ

អនុប្រធានគណៈកម្មការ គឺជាអ្នកទទួលបន្ទុកលើការងាររួមក្នុងកំឡុងពេលអវត្តមានរបស់ប្រធានគណៈកម្មការ ។

### គ. -ផ្នែកនីមួយៗ

អ្នកទទួលបន្ទុកផ្នែកនីមួយៗ ជាអ្នកដឹកនាំសមាជិកក្រុមអនុវត្តការងារ និងផ្សព្វផ្សាយពត៌មានដែលទទួលបានមក ហើយធ្វើការត្រួតពិនិត្យ និងវាយតំលៃលើការងារក្រុម ព្រមទាំងលើកជាគំនិតសំរាប់ដាក់បញ្ចូលក្នុងផែនការអនុវត្តការងាររួចបញ្ជូនទៅកាន់ប្រធានគណៈកម្មការ ដើម្បីសំរេច ។

### ឃ. -សមាជិកសហគមន៍នេសាទ

សមាជិកសហគមន៍នេសាទទាំងអស់ មានភារកិច្ចអនុវត្តរាល់ការងារដែលគណៈកម្មការ និងប្រធានផ្នែកនីមួយៗ បានប្រគល់ជូន ពិសេស ត្រូវចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មការអណ្តត្តិថ្មី និងផ្តល់ជាគំនិត ដើម្បីអោយដំណើរការសហគមន៍នេសាទមានការអភិវឌ្ឍន៍បាន ។

### ៦. -តួនាទីរបស់បុរស -ស្ត្រីចូលរួមក្នុងដំណើរការនៃសហគមន៍នេសាទ

ថ្វីត្បិតតែ បុរសមានឱកាសរកការងារបានប្រសើរជាងស្ត្រីពិតមែន ប៉ុន្តែ បច្ចុប្បន្នស្ត្រីត្រូវបានគេសង្កេតឃើញថាកំពុងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការងារប្រពន្ធ័ផ្សព្វផ្សាយ ។ ក្នុងការអភិវឌ្ឍន៍សហគមន៍នេសាទចាំបាច់ត្រូវមានការចូលរួមទាំងបុរសនិងស្ត្រី ដើម្បីអនុវត្តការងារ ព្រមទាំងការធ្វើសេចក្តីសំរេចចិត្ត ពិសេស សំរាប់ស្ត្រីដោយហេតុថា ពួកគេនៅផ្ទាល់និងការប្រើប្រាស់ធនធានទាំងនេះជាប្រចាំថ្ងៃ។ ជាក់ស្តែង រាល់ការធ្វើសេចក្តីសំរេចចិត្តរបស់ស្ត្រីក្នុងការចូលរួមនៃដំណើរការគ្រប់គ្រងសហគមន៍នេសាទទាំងពីរនេះនៅមានកំរិត គឺប្រហែល ៤០ភាគរយនៃបុរស ពីព្រោះថាទាក់ទងជាមួយប្រពៃណី ទំនៀមទំលាប់ ការរវល់មមាញឹកក្នុងការថែរក្សាកូនតូច ជាងនេះខ្វះខាតការលើកទឹកចិត្ត និងការផ្សព្វផ្សាយអោយបានទូលាយដល់ស្ត្រីទាំងនោះ។

ទោះបីជាចំនួនស្ត្រីតិចជាងបុរសពិតមែន ក៏ពួកគាត់មានសិទ្ធិគ្រប់គ្រាន់ក្នុងការពិភាក្សា ផ្តល់ជាគំនិត ផ្លាស់ប្តូរយោបល់ និងការចូលរួមធ្វើផែនការគ្រប់គ្រងជាមួយបុរសផងដែរ លើសពីនេះពួកគាត់បានទទួលតួនាទីជាអនុប្រធានគណៈកម្មការសហគមន៍ ផ្នែកបេឡា និងផ្នែកផ្សព្វផ្សាយ ។

### ៦. សិទ្ធិ និងការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋានលើធនធានជលផល

សហគមន៍មូលដ្ឋានភាគច្រើន មានការសប្បាយចិត្តយ៉ាងខ្លាំងដោយបានទទួលសិទ្ធិក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលនៃសហគមន៍នេសាទនេះ ។ ជាក់ស្តែង ក្នុងឆ្នាំ២០០០ អ្នកភូមិមួយចំនួនបានឈរឈ្មោះតំណាងគណៈកម្មការសហគមន៍នេសាទ ហើយអ្នកភូមិដ៏ទៃទៀតបានចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត ដើម្បីជ្រើសរើសគណៈកម្មការសំរាប់អណ្តត្តិទី២ព្រមទាំងពួកគាត់បានចូលរួមក្នុងការបញ្ចេញមតិ និងការផ្លាស់ប្តូរយោបល់លើការរៀបចំផែនការគ្រប់គ្រងនៃធនធាននេះ ។ លើសពីនេះ ពួកគាត់មានការទទួលខុសត្រូវខ្ពស់លើការធ្វើល្បាតក្នុងរង្វង់ដែននេសាទនៃសហគមន៍ ដើម្បីជៀសវាងបាននូវការធ្វើនេសាទបែបអនាធិបតេយ្យ ។ នេះជាចំណុចសំខាន់ដែលពួកគាត់មានភាពជាម្ចាស់លើការទទួលខុសត្រូវនូវការគ្រប់គ្រង លើធនធានជលផលអោយបានប្រសើរឡើង ប៉ុន្តែអាជ្ញាធរមូលដ្ឋានហាក់បីដូចមានការគាំទ្រពុំទាន់ពេញលេញ និងសហការអោយបានជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋានក្នុងការដោះស្រាយនូវបទល្មើសដែលបានកើតឡើងនៅឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ពេលខ្លះពួកគេមួយភាគតូចឆ្លៀតឱកាសរួមជាមួយអ្នកមានអំណាច និងល្មើសជនប្រដាប់អាវុធ ដើម្បីទាញយកផលប្រយោជន៍សំរាប់បំរើសេចក្តីត្រូវការរបស់ពួកគេផ្ទាល់ ។ គួបផ្សំនឹងអនុក្រឹត្យសហគមន៍នេសាទពុំទាន់អនុម័តផងនោះ បានធ្វើអោយអ្នកមានអំណាចខ្លះប្រើសិទ្ធិកៀបសង្កត់មកលើពួកគាត់ ជាហេតុធ្វើអោយអ្នកភូមិមួយចំនួនតូចពុំទាន់ជឿជាក់លើការគ្រប់គ្រង និងសិទ្ធិទទួលខុសត្រូវលើធនធានដោយខ្លួនឯង ។

ទោះបីជាយ៉ាងនេះក្តី សហគមន៍មូលដ្ឋានស្ទើរតែទាំងអស់មានសុច្ឆន្ទៈទទួលខុសត្រូវ និងចូលរួមថែរក្សាលើធនធានទាំងនេះប្រកបដោយដំណើរការយ៉ាងល្អប្រសើរ ។ ជាងនេះ ពួកគាត់មានសិទ្ធិគ្រប់គ្រាន់លើការនេសាទ ហើយមិនចាំបាច់បង់ពន្ធជូនរដ្ឋដូចក្នុងរបបសាធារណរដ្ឋកម្ពុជាឡើយ ដោយគ្រាន់តែពួកគេត្រូវអនុវត្តគោរពលក្ខន្តិកៈរបស់សហគមន៍នេសាទ ។

### ៧. ការបង្កើនចំណេះដឹង និងផ្សព្វផ្សាយពត៌មាននានាដល់សហគមន៍ដ្ឋាន

ក្រោយពីការបង្កើតសហគមន៍រួចមក ស្ថាប័នជំនាញជលផលថ្នាក់ជាតិ ពុំទាន់បានធ្វើការផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសនានា និងបញ្ចូនពត៌មានផ្សេងៗ ដែលទាក់ទងជាមួយសហគមន៍ ដើម្បីអោយពួកគេយល់ដឹងពីការចែករំលែកអំណាចដល់ថ្នាក់មូលដ្ឋានដែលស្របគោលនយោបាយវិមជ្ឈការនៃរដ្ឋាភិបាលនៅឡើយ ។ ប៉ុន្តែពីមន្ត្រីតំរោងដែលធ្វើការងារផ្ទាល់ជាមួយសហគមន៍មូលដ្ឋានបានផ្សព្វផ្សាយពត៌មានពាក់ពន្ធ័ក្នុងការគ្រប់គ្រងធនធានជលផលតាមរបៀបសហគមន៍នេសាទ ដោយបានបើកសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំពិភាក្សាលើការងារផ្សេងៗ ពិសេស កងកំលាំងប្រដាប់អាវុធត្រូវតែយល់ដឹងច្បាស់លាស់អំពីទំនាក់ទំនងនៃការចូលរួមគ្រប់គ្រងវារីជីវចំរុះជលផលដោយសហគមន៍មូលដ្ឋាន ពីព្រោះថា ស្ថាប័ននេះមានកាតព្វកិច្ចចំបងដើម្បីចូលរួមចំណែកជួយទប់ស្កាត់បទល្មើសនេសាទដែលបានកើតឡើង ជាងនេះត្រូវមានកិច្ចសហការអោយជិតស្និទ្ធិជាមួយសហគមន៍មូលដ្ឋានក្នុងការជំរុញអោយដំណើរការសហគមន៍នេសាទមានភាពរលូនទៅមុខ ។

## ៨. សន្និដ្ឋាន

ប្រសិនបើធនធានធម្មជាតិមានការគ្រប់គ្រងបានល្អ វានឹងបានផ្តល់នូវផលប្រយោជន៍យ៉ាងយូរអង្វែងសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅជាប្រចាំថ្ងៃដល់សហគមន៍មូលដ្ឋាន ប៉ុន្តែធនធានដ៏មានតំលៃសេដ្ឋកិច្ចខ្ពស់ទាំងនេះ កំពុងតែរងនូវការដកហូតយកផលប្រយោជន៍ហួសពីលទ្ធភាពផ្តល់អោយបានថយចុះគួរចាប់អារម្មណ៍ ដោយសារអ្នកនេសាទខាងក្រៅរួមជាមួយកងកំលាំងប្រដាប់អាវុធ និងអ្នកមានអំណាចមួយចំនួន។ ដោយបានជួបសកម្មភាពបំផ្លិចបំផ្លាញបែបនេះ តួបផ្សំនឹងកិច្ចសហការរវាងស្ថាប័នជំនាញ អង្គការ OCAA ការគាំទ្រពីអាជ្ញាមូលដ្ឋាន និងការចូលរួមយ៉ាងសកម្មពីសហគមន៍មូលដ្ឋានផងនោះ សហគមន៍នេសាទត្រូវបានបង្កើតឡើង ដែលបណ្តាលអោយបទល្មើសនេសាទត្រូវបានកាត់បន្ថយមួយចំនួនធំ។

ម្យ៉ាងវិញទៀត សហគមន៍មូលដ្ឋានមានការយល់ដឹងយ៉ាងច្រើនពីសារប្រយោជន៍នៃការប្រើប្រាស់ធនធានជលផលតាមរយៈការជួយជ្រោមជ្រែងរបស់មន្ត្រីសំរបសំរួលតំរោងដូចជា ការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការដឹកនាំសមាជិកសំខាន់ទៅធ្វើទស្សនកិច្ចនៅតំបន់ផ្សេងៗ ដើម្បីរៀនសូត្របទពិសោធន៍ក្នុងគោលបំណងជំរុញអោយសហគមន៍នេសាទរបស់ខ្លួន មានការអភិវឌ្ឍន៍។ បច្ចុប្បន្ន ធនធានជលផលនៅក្នុងសហគមន៍នេសាទត្បូងខ្លា និងអូរគ្រះមានលក្ខណៈល្អប្រសើរជាងមុនការបង្កើតសហគមន៍ពីព្រោះថា មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ មានតួនាទីនិងការទទួលខុសត្រូវពិតប្រាកដ ហើយសហគមន៍មូលដ្ឋានយល់អំពីតំលៃនៃធនធាន ព្រមទាំងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់មានការថយចុះយ៉ាងច្រើន បើប្រៀបធៀបពីពេលមុនការបង្កើតសហគមន៍នេសាទ និងសហគមន៍មូលដ្ឋានទទួលបាននូវសិទ្ធិក្នុងការប្រកបរបរនេសាទ ដោយពុំចាំបាច់ធ្វើការបង់ពន្ធជូនរដ្ឋដូចពីពេលមុន។ ចំណុចទាំងនេះ ដែលជំរុញអោយសហគមន៍មូលដ្ឋានបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

## ៩. អនុសាសន៍

-សមាជិកសហគមន៍ គួរតែឈរលើគោលការណ៍អព្យាក្រិត្យ មិនប្រកាន់យកគណបក្សនយោបាយណាមួយ ពិសេសត្រូវតែមានសុច្ឆន្ទៈទាំងអស់គ្នា នោះទើបដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ មានភាពជឿនលឿន។

-ដើម្បីជំរុញអោយដំណើរការសហគមន៍នេសាទមានភាពល្អូតលាស់ប្រសើរឡើង លុះត្រាតែស្ថាប័នជំនាញពាក់ព័ន្ធ អង្គការជួយឧបត្ថម្ភសំភារៈ ព្រមទាំងស្មារតី ដើម្បីទំនុកបំរុងដល់សហគមន៍មូលដ្ឋាន។ ជាងនេះ គួរតែមានការចូលរួមសហការយ៉ាងជិតស្និទ្ធពីអាជ្ញាធរមូលដ្ឋាន កងកំលាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធ។

-ដើម្បីធានាបាននូវផលប្រយោជន៍យូរអង្វែង ក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលបានសមស្រប ចាំបាច់មន្ត្រីជំនាញត្រូវផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសនានា ដែលទាក់ទងនិងការចូលរួមគ្រប់គ្រងធនធានជលផលដោយសហគមន៍ មូលដ្ឋាន។

-លើសពីនេះ អង្គការនេះគួរតែបណ្តុះបណ្តាលបន្ថែមដល់គណៈកម្មការ និងសមាជិកសហគមន៍សំខាន់ៗ តាមរយៈការនាំពួកគេទៅធ្វើទស្សនកិច្ចសិក្សានៅតំបន់ផ្សេងៗ ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ ដើម្បីអោយពួកគេអាចជួយធ្វើអោយសហគមន៍នេសាទខ្លួនឯងអភិវឌ្ឍន៍បានល្អ។

-ដើម្បីទប់ស្កាត់ជនល្មើសដែលឆ្លៀតឱកាសយកឥទ្ធិពលរបស់ខ្លួន ធ្វើការទាញយកផលប្រយោជន៍ផ្ទាល់ពីធនធាននេះស្ថាប័នទទួលខុសត្រូវ ត្រូវតែជំរុញអនុក្រឹត្យសហគមន៍នេសាទអនុម័តបានលឿន។

-ដើម្បីជៀសវាងនូវការរាំងស្ទះក្នុងដំណើរការរីកចំរើនរបស់សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ពិសេស កងកំលាំងប្រដាប់អាវុធ ត្រូវតែបង្ករលក្ខណៈងាយស្រួល ព្រមទាំងផ្តល់សិទ្ធិ និងការទទួលត្រូវគ្រប់គ្រាន់ដល់សហគមន៍មូលដ្ឋានលើការ ចូលរួមថែរក្សា និងការធ្វើនេសាទប្រកបដោយសមស្រប។

## ១០. ប្រវត្តិនៃគំរោងស្តីពី "អង្គការសហគមន៍ជំនួយបរទេស"

អង្គការសហគមន៍ជំនួយបរទេសមានមូលដ្ឋានធំនៅភ្នំពេញដែលមានតំបន់គោលដៅ ៣រួមមាន ខេត្តតាកែវ ក្រចេះនិងខេត្តស្ទឹងត្រែង។ ដោយឡែក អង្គការសហគមន៍ជំនួយបរទេសក្នុងខេត្តស្ទឹងត្រែង បានចាប់ផ្តើមអនុវត្តការងាររបស់ខ្លួនក្នុងឆ្នាំ ១៩៩៧ ហើយអង្គការនេះ បានធ្វើការងារផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរជំនាញក្នុងខេត្តដូចជា មន្ទីកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសុខាភិបាល និងបណ្តាញការងារអង្គការផ្សេងៗទៀត។ អង្គការនេះ បានផ្តោតលើការជួយទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ដោយបង្កើតជាឥណទានខ្នាតតូចព្រមទាំងបានជួយរៀបចំសហគមន៍នេសាទ ដើម្បីជំរុញអោយប្រជាជនយល់ពីការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាពនិងជួយកាត់បន្ថយបាននូវបទល្មើសនេសាទ។ ជាការពិតណាស់ អង្គការនេះបានកសាងសមត្ថភាពសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋានព្រមទាំងមន្ត្រីសមាសភាគីនៅក្នុងស្ថាប័នបច្ចេកទេស អំពីទស្សនៈសំខាន់ៗដែលទាក់ទងនិងការចូលរួមគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍នេសាទដោយបានបើកជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងនាំពួកគេទាំងនោះទៅធ្វើទស្សនកិច្ចសិក្សាក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ ដើម្បីធ្វើអោយសហគមន៍នេសាទរបស់ខ្លួនមានការអភិវឌ្ឍន៍។

គោលបំណងរបស់អង្គការសហគមន៍ជំនួយបរទេសរួមមាន:

**១-និរន្តភាពនៃជីវភាពរស់នៅ**

- ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ នឹងបានផ្តល់អោយនូវអាហារ និងចំណូល
- ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ នឹងមានដំណើរការល្អសំរាប់ការអនុវត្តការងារដូចជាកំលាំងពលកម្ម សិទ្ធិដែលធ្វើអោយលក្ខណ្ឌការងាររបស់ពួកគេបានល្អប្រសើរ។

**២-មានសិទ្ធិក្នុងការព្យាបាល និងការអប់រំ**

-ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ នឹងបានផ្តល់អោយជាថ្នាំសំរាប់ជួយអោយសុខភាពល្អប្រសើរ និងជួយផ្គត់ផ្គង់ទឹកស្អាតព្រមទាំងអនាមយ័ទៀតផង។

-កុមារដែលរស់នៅក្នុងភាពក្រីក្រ នឹងបានផ្តល់សិទ្ធិក្នុងការចូលរៀន ព្រមទាំងផ្តល់ឱកាសគ្រប់គ្រាន់ដល់យុវយ័ក្រខ្សត់អោយបានបន្តការសិក្សា ដើម្បីជួយកែលំអជីវភាពរបស់ខ្លួនបានប្រសើរ។

**៣-ស្ថានភាពរស់នៅ និងសន្តិសុខ**

-ប្រជាជនតិចតួចដែលនឹងស្លាប់ មានជម្ងឺ រងរបួសពីសមរភូមិ ឬ រងគ្រោះដោយធម្មជាតិ ត្រូវបានគាំទ្រទាំងផ្នែកស្មារតីនិងសំភារៈ។

-ប្រជាជនតិចតួចដែលនឹងរងនូវអំពើឃោរឃៅ ការបង្ខិតបង្ខំអោយផ្លាស់ទីលំនៅ ឬគ្រោះថ្នាក់ដោយសង្គ្រាមនឹងត្រូវបានធានាសន្តិសុខ។

**៤-សិទ្ធិក្នុងការនិយាយ**

-មនុស្សដែលស្ថិតក្នុងស្រទាប់ទាបនឹងត្រូវផ្តល់សិទ្ធិក្នុងការនិយាយ និងការធ្វើសេចក្តីសំរេចចិត្តក្នុងដំណើរការរស់នៅព្រមទាំងផ្តល់អោយនូវសិទ្ធិនយោបាយ និងសិទ្ធិរស់នៅ ហើយក៏មានឋានៈស្មើនិងអ្នកផ្សេងទៀតដែលរស់នៅក្នុងសង្គម

**៥-សមភាពយេនឌ័រ**

-ស្ត្រី និងបុរស់មានសិទ្ធិស្មើគ្នាក្នុងការចូមរួមការងារសង្គម

ជាលទ្ធផលក្នុងកំឡុងឆ្នាំ ១៩៩៧ ដល់ ២០០២ អង្គការនេះបានសំរេចជ្រើសរើស ២៩ភូមិសំរាប់ធ្វើការងាររបស់ខ្លួន ក្នុងនោះ ១៦ភូមិស្ថិតនៅស្រុកសៀមបូក និង១៣ភូមិ នៅក្នុងស្រុកថាឡាបរិវ៉ាត់ ដោយបានបង្កើតជាគណៈកម្មការតូច ដើម្បីទ្រទ្រង់ជីវភាពរស់នៅនៃសហគមន៍មូលដ្ឋាន។ ជាពិសេស មន្ត្រីគំរោងបានជួយសំរបសំរួលក្នុងការរៀបចំសហគមន៍នេសាទ ដែលសំរេចបានចំនួន ២៩សហគមន៍នេសាទ។ លើសពីនេះ អង្គការនេះ បានកសាងសមត្ថភាពដល់អ្នកភូមិស្ថិពីការប្រើប្រាស់ធនធានត្រីប្រកបដោយនិរន្តភាព ដើម្បីជំរុញដល់សហគមន៍មូលដ្ឋានចូលរួមក្នុងការការពារ ការអភិរក្ស និងការត្រួតពិនិត្យអោយបានត្រឹមត្រូវលើជីវចំរុះជលផល ព្រមទាំងការអប់រំផ្នែកបរិស្ថានដល់ពួកគេទៀតផង។ ម្យ៉ាងទៀត អង្គការកំពុងបានកសាងសមត្ថភាពមន្ត្រីសមាសភាគី និងស្ថាប័នពាក់ពន្ធ័ ដើម្បីពង្រឹងការចូលរួមគ្រប់គ្រងធមធានធម្មជាតិ។ ជាការពិត យុទ្ធសាស្ត្រចំបងនៃអង្គការ អូស៊ីអេអេ មានរាងត្រីកោណ ហើយកំពុងបានជួយសំរបសំរួលដល់ស្ថាប័នរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ដើម្បីអោយពួកគេសហការគ្នា ព្រមទាំងមានទំនាក់ទំនងល្អជាមួយគ្នា និងចូលរួមការពារធនធានធម្មជាតិរបស់ខ្លួន ពិសេស ធនធានជលផលដែលស្ថិតនៅតាមដងទន្លេមេគង្គ។

ឆ្នាំនេះ អង្គការ អូស៊ីអេអេ នឹងពង្រីកសហគមន៍នេសាទក្នុងចំនួន ៥ភូមិ ដែលស្ថិតនៅក្នុងស្រុក សេសាន ។

- **បណ្តាញការងារគំរោង**

អង្គការទាំងអស់ និងស្ថាប័នរដ្ឋាភិបាលក្នុងខេត្តស្ទឹងត្រែងបានចូលរួមប្រជុំជាប្រចាំខែ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា។ អង្គការទាំងនោះមាន: ភិអេហ្វឌី សិទ្ធកុមា សេដាំ វីវែម ។ល។

- **លទ្ធផលជាវិជ្ជមានរបស់អង្គការ អូស៊ីអេអេ**

ដំណើរការសរសេររបាយការណ៍ករណីសិក្សានេះ ជាចំណុចសំខាន់ដែលបានចែករំលែកនូវជំនាញសំរាប់សរសេរទៅដល់មន្ត្រីគំរោងនៃអង្គការ និងមន្ត្រីសមាសភាគីនៃស្ថាប័នជំនាញ។ ពិសេស ពួកគេបានទទួលនូវទស្សនៈសំខាន់ៗ ដែលទាក់ទងការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ដើម្បីឆ្លុះបញ្ចាំងដល់សកម្មភាពគំរោង និងការអនុវត្តផ្សព្វផ្សាយពត៌មានដល់សហគមន៍មូលដ្ឋាន។ ដំណើរការចងក្រងនេះបានជួយផ្តល់ដល់យើងពីចំណុចខ្លាំង និងចំណុចខ្សោយដែលគំរោងកំពុងតែអនុវត្តលើការងាររបស់ខ្លួន ហើយយើងនឹងឈានដល់ការបង្កើតសកម្មភាពជាក់លាក់ ដើម្បីធ្វើអោយដំណើរការនៃការងារអង្គការមានលក្ខណៈល្អប្រសើរ។

**អាសយដ្ឋានទាក់ទង**: Mobilephone: ០១២៩៨០៤១៥
Email.012980415@mobitel.com.kh ។ (ខេត្តស្ទឹងត្រែង)

**អាសយដ្ឋានទាក់ទងភ្នំពេញ**

ផ្ទះលេខ ៥៤, ផ្លូវ ៣៥២, សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន, ភ្នំពេញ
Tel: ០២៣ ៧២០ ០៣៦, ៧២០ ៩២៨

Mobile: ០១៦ ៨៤៦៥៥៦
Email: thavy_caa@pigbond.com.kh

## ប្រវត្តិគំរោង : "ករណីសិក្សាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម និងបណ្តាញការងារ"

ករណីសិក្សាស្តីពី "ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ត្រូវបានសំរបសំរួលដោយស្ថាប័នចំរុះ និងក្រុមស្នូលស្រាវជ្រាវនៅ ក្នុងប្រទេសកម្ពុជា ព្រមទាំងដៃគូសហការផ្សេងៗ។ ជាងនេះមានសមាសភាពចូលរួមពីស្ថាប័ន ផ្សេងៗ ដូចជា ស្ថាប័នរាជរដ្ឋាភិបាល ក្រុមអង្គការ ស្ថាប័នបណ្តុះបណ្តាល និងសហគមន៍មូលដ្ឋាន សង្គមស៊ីវិលដែលកំពុងបានអនុវត្តការងារនៅតំបន់ខ្ពង់រាប ទំនាបកណ្តាល តំបន់មេគង្គ ព្រមទាំងតំបន់ឆ្នេរ។

គំរោងស្តីពី "ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" ត្រូវបានឧបត្ថម្ភដោយអង្គការមួយចំនួនដូចជា :

-អង្គការកម្មវិធីអភិរក្សធនធានធម្មជាតិពិភពលោក

-អង្គការមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍

-អង្គការមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់

-អង្គការបណ្តុះបណ្តាល ស្រាវជ្រាវ និងបណ្តាញការងារនៅបំបន់មេគង្គ

គំរោងនេះបានគាំទ្រដល់ទំនាក់ទំនងជាមូលដ្ឋានដែលបានអនុម័ត ផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពដោយឆ្លងកាត់:

-សហគមន៍ព្រៃឈើ

-សហគ្រប់គ្រងធនធានជលផល

-ការចូលរួមធ្វើផែនការប្រើប្រាស់ដី ការចូលរួមគ្រប់គ្រងក្នុងតំបន់ការពារ។

ទិសដៅចុងទៅរបស់គំរោងនេះ គឺជួយជំរុញអោយការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម ស្ថិតនៅជាផ្នែកមួយយ៉ាងពិតប្រាកដនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងជាក់លាក់របស់គំរោងគឺ

- ការកសាងសមត្ថភាព
- រៀនសូត្រពីបទពសោធន៍
- បណ្តាញការងារ
- ការគាំទ្រគោលនយោបាយ

សកម្មភាពបន្តរបស់កម្មវិធីគំរោងរួមមានការបង្កើតឡើងនូវទស្សនៈសំខាន់ៗព្រមទាំងការវិភាគលើគ្រោងការណ៍សំរាប់អនុវត្តលើគំរោង "ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" នៅកម្ពុជា។ ជាងនេះ ការកសាងសមត្ថភាពដោយឆ្លងកាត់ការអនុវត្តសរសេររបាយការណ៍ករណីសិក្សា ដើម្បីបង្កើនការស្រាវជ្រាវការរៀបចំឯកសារ ជំនាញវិភាគ និងការកសាងបណ្តាញការងាររវាងអ្នកគាំទ្រ "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម" ទូទាំងប្រទេស និងថ្នាក់តំបន់ព្រមទាំងការគាំទ្រនូវដំណើរការពិគ្រោះយោបល់សំរាប់ការអភិវឌ្ឍន៍ គ្រោងការណ៍ពាក់ព័ន្ធស្របច្បាប់។

### អង្គការដែលជាដៃគូអនុវត្តការងារជាមួយគំរោង "ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម"

- នាយកដ្ឋានអភិរក្សនិងការពារធនធានធម្មជាតិ( ក្រសួងបរិស្ថាន)
- នាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ ( ក្រសួងកសិកម្ម)
- នាយកដ្ឋានជលផល( ក្រសួងកសិកម្ម)
- អង្គការមូលនិធិសំរាប់ធនធានធម្មជាតិ
- មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសំរាប់ការអភិវឌ្ឍន៍
- មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើថ្នាក់តំបន់
- អង្គការបណ្តុះបណ្តាល ស្រាវជ្រាវ និងបណ្តាញការងារនៅបំបន់មេគ
- អង្គការអុកស្វាមអាមេរិកាំង
- គំរោងស្តីពី ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាងនៅតំបន់ឆ្នេរ
- តំបន់ឧទ្យានជាតិរាម នៃក្រុងព្រះសីហនុ
- អង្គការឌុនសីន
- អង្គការជំនួយសហគមន៍បរទេសនៃអុកស្វាម( ស្ទឹងត្រែង)
- គំរោងស្តីពី " ការស្រាវជ្រាវសហគមន៍ព្រៃឈើ"
- គំរោងស្តីពី " អនុផលព្រៃឈើ" ( រតនៈគិរី)
- គំរោងស្តីពី " អតិបាលកិច្ច សំរាប់ភាពជាដៃគូ"
- អង្គការហ្សាវ ( សៀមរាប)
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាកលវិទ្យាល័យភ្នំពេញ ( មហាវិទ្យាល័យ នៃវិទ្យាសាស្ត្របរិស្ថាន
- ក្រុមការងារសហគមន៍ព្រៃឈើ
- ក្រុមការងារសំរាប់ឡាប់ជលផល
- ក្រុមការងារបណ្តុះបណ្តាលផែនការចូលរួមគ្រប់គ្រងដីធ្លី
- បណ្តាញការងារសហគមន៍ព្រៃឈើ
- វេទិការបស់អង្គការក្រៅរដ្ឋាភិបាល ស្តីពីបរិស្ថាន

fishing areas (for daily needs). The villagers limit fishing equipment in order to fit the situation of the fishing area.

As well, the community regulations have clarified the role of community committees and members, and added a prohibitory notice for halting anarchic fishing activities. In the past they didn't have full rights to join in the management and exploitation of the fish resource, local people recognize this is the best chance they have to make decisions regarding responsibility for fisheries resource conservation. Also, the government's policy of decentralization may enable them to receive equal benefits from the fishery resource.


Increased fish products after the establishment of the community fishery

The local communities are still limited in fisheries resources management capacity; even the technical officers of governmental agencies lack experience in planning for managing community fisheries. However, most local people through the facilitation of OCAA and the provincial fishery office are working towards improved management, step by step.

**5) Clear Role and Structure of Management of Community Fisheries in Tboung Khlar and Omreah**

The above section shows how and why community fisheries came to be. This section describes the structure and functioning of the community fisheries.

The Community Fishery is a part of the community development committee. Its committee is elected from the local community and plays the role of managing the sustainable use of fisheries resources.



# COMMUNITY PARTICIPATION IN FISHERIES MANAGEMENT

**A Case Study**

*from Tboung Khlaa and O Mreah Villages*
*Stung Treng Province*
*Kingdom of Cambodia*


**Researched and Written by:**
*Khai Syrabo*
*Thai Kimseng*

**Coordinated by:**
*Oul Kim Sear*


**2002**

# Community Participation in Fisheries Management

## A Case Study

